fidh

# ឈូសឆាយដីសំរាប់ដំណាំកៅស៊ូ, បំផ្លាញសិទ្ធិផ្សេងៗ

## ប៉ះពាល់ពីការដាំដំណាំកៅស៊ូដោយក្រុមហ៊ុន សុខហ្វីន ខេស៊ីឌី លើសហគមន៍ ជនជាតិដើមភាគតិចនៅប៊ូស្រា, មណ្ឌលគីរី

**Summary in Khmer**

Article 1: All human beings are born free and equal in dignity and rights. They are endowed with reason and conscience and should act towards one another in a spirit of brotherhood. Article 2: Everyone is entitled to all the rights and freedoms set forth in this Declaration, without distinction of any kind, such as race, colour, sex, language, religion, political or other opinion, national or social origin, property, birth or other status. Furthermore, no distinction shall be made on the basis of the political, jurisdictional or international status of the country or territory to which a person belongs, whether it be independent, trust, non-self-governing or under any other limitation of sovereignty. Article 3: Everyone has the right to life, liberty and security



November 2011
N°574k

# របាយការណ៍សង្ខេប

ដីសម្បទានសេដ្ឋកិច្ច គឺជាកិច្ចសន្យាធានារយៈពេលយូរលើដី ដើម្បីទាញយកប្រយោជន៍ពីដីកសិឧស្សាហកម្ម។ ច្រើនឆ្នាំកន្លងទៅ ការធ្វើសម្បទានសេដ្ឋកិច្ចនៅប្រទេសកម្ពុជាមានសន្ទុស្សន៍កើនឡើងជាលំដាប់ និងជាប្រធានបទរិះគន់យ៉ាងធ្ងន់ធ្ងរពីអង្គការសង្គមស៊ីវិលក្នុងស្រុក និងអន្តរជាតិ លើការរំលោភសិទ្ធិមនុស្ស និងដែលកាត់បន្ថយនូវអ្វីដែលជាធនធានសំរាប់អាយុជីវិត និង ការរស់នៅប្រចាំថ្ងៃរបស់សហាគមន៍ ដែលធ្វើឲ្យភាពក្រីក្រកាន់តែធ្ងន់ធ្ងរឡើងៗ។ ការប្តឹងផ្តល់សកម្មជនសិទ្ធិមនុស្សនៅកម្ពុជា កាន់តែមានចំនួនកើនឡើង។

ក្នុងឆ្នាំ២០០៨ ដីសម្បទានសេដ្ឋកិច្ចមួយ ដើម្បីទាញយកផលចំនេញក្នុងវិស័យឧស្សាហកម្មនៃការដាំដំនាំកៅស៊ូ ត្រូវបានធានាដោយប្រទេសកម្ពុជាអោយក្រុមហ៊ុនខៅជូលីគ្រុប(KCD) ដែលជាក្រុមហ៊ុនសហាការយ៉ាងស្អិតរមួតជាមួយរដ្ឋាភិបាលកម្ពុជា។

នៅឆ្នាំ២០០៧ មានក្រុមហ៊ុនមួយឈ្មោះ សុខហ្វីនបានចូលមកដាក់ទុនជាមួយ ក្រុមហ៊ុនខៅជូលីគ្រុប(KCD) ដាក់ឈ្មោះថា សុខហ្វីន ខេស៊ីឌី ដែលមានភាគហ៊ុន៨០% និងដែលធានានូវរាល់ការប្រតិបត្តិការរបស់ខ្លួន។ ដែលចុះឈ្មោះនៅ**លុចហ្សំបួរ** ក្រុមហ៊ុនសុខហ្វីនគឺត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនបារាំងពីរក្រុម គឺបូឡូរ៉ា និង ប៉ែលហ្គេន ដែលជាស្រឡាយរបស់ក្រុមហ៊ុនហ្វៃប្រ៊ី និង រីប។

បច្ចុប្បន្ន សុខហ្វីន ខេស៊ីឌីរៀបចំដីសម្បទានចំនួនពីរកន្លែងនៅក្នុងទឹកដីប៊ូស្រា នៃខេត្តមណ្ឌលគីរី(រ៉ាប៉ាណាស៊ី និង សេដ្ឋីកូឡា) ដែលមានចំនួនដីសរុបចំនួន ៧០០០ហិកតា។ ដីសម្បទានទាំងនោះត្រូវបានប៉ះពាល់ប្រជាពលរដ្ឋដែលកំពុងរស់នៅឃុំប៊ូស្រាចំនួន៨៥០គ្រួសារ។ ៩០%នៃប្រជាជននៅក្នុងឃុំប៊ូស្រាជាជនជាតិព្នង ដែលជាក្រុមជនជាតិដើមភាគតិចនៃព្រះរាជាណាចក្រកម្ពុជា។ ព្នងប្រកបរបរចិញ្ចឹមជីវិតដោយធ្វើចំការវិលជុំហើយដែលពឹងផ្អែកទាំងស្រុងលើការបោចវល្លិ៍

និងផលិតផលមួយចំនួនបានមកពីរុក្ខជាតិ។ជនជាតិព្នងគោរពនិងជឿលើព្រៃអារក្សអ្នកតា ដែលពួកគេជឿថាវិញ្ញាណទាំងអស់នោះនៅតាមរក្សាការពារព្រៃរបស់ពួកគេហេតុនេះពួកគេនៅថែរក ្សាព្រៃអារក្ស និងផ្នូរដូនតារបស់ពួកគេដោយមិនអោយអ្នកណាប៉ះពាល់ឡើយ។

មានការរិះគន់ពីអង្គការមួយចំនួនដែលជាសមាជិកនៅប្រទេសកម្ពុជា ពីភាពមិនប្រក្រដីជាច្រើន និងការរំលោភសិទ្ធិមនុស្ស កាលពីខែ ធ្នូ ឆ្នាំ ២០១០ ហ្វីដ(FIDH)មានការធ្វើបេសកកម្មអន្តរជាតិមួយ ដើម្បីធ្វើការស៊ើបអង្កេតដោយផ្ទាល់។

## ការរំលោភសិទ្ធិជនជាតិដើមភាគតិច ដើម្បីទទួលបានកម្មសិទ្ធិរួម ឬ សិទ្ធិជាសមូសហភាព

*មានគោលនយោបាយដើម្បីគាំទ្រជនជាតិដើមភាគតិច*
*ប៉ុន្តែយើងបានសួរពួកគាត់ដើម្បីផ្លាស់ប្តូរទំលាប់របស់ពួកគេ។*
*ពួកគេត្រូវការធ្វើចំការនៅតំបន់ណាមួយជាក់លាក់និង*
*ឈប់ធ្វើចំការពនេចរទៀតបើពុំដូចនោះទេពួកគេពុំអាចជៀសផុតពីភាពក្រីក្របានឡើយ។*
*(អាជ្ញាធរថ្នាក់ខេត្តបានមានប្រសាសន៍)*

គំពោងកំណែទំរង់ច្បាប់កម្ពុជា សំរាប់ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច ដូចស្មារតីច្បាប់កម្ពុជា និង ដើម្បីការពារសិទ្ធិជនជាតិដើមភាគតិចក្នុងការទទួលបានកម្មសិទ្ធិរួមឬ សិទ្ធិជាសមូសហភាព។ ទោះបីជាក្រុមគ្រួសារជនជាតិដើមភាគតិចនៅប៊ូស្រារៀបរាប់ពីតំរូវការចាំបាច់របស់ពួកគេយ៉ាងណាក៏ដោ យ ក៏ពួកគេនៅតែប្រឈមនឹងបញ្ហានយោបាយជាច្រើន មានទាំងឧបសគ្គនៃរដ្ឋបាល និង បទដ្ឋានផ្សេងៗ ដែលជាការលំបាកយ៉ាងខ្លាំងដល់ពួកគេដើម្បីស្វែងរកដំណោះស្រាយ ឲ្យមានកម្មសិទ្ធិសមូហភាពស្របច្បាប់មុននឹងក្រុមហ៊ុន សុខហ្វីន ខេស៊ីឌីមកចាប់ផ្តើមឈូសឆាយដីរបស់ពួកគេ។ ក្រុមគ្រួសារប្រជាជននៅប៊ូស្រា គួរតែទទួលបាននូវសំណងសំរម្យដែលជាតំរូវចាំបាច់របស់ពួកគាត់ទៅតាមអ្វីដែលមានចែងក្នុងច្បាប់ក ម្ពុជា បេសកម្មរបស់ហ្វីដ(FIDH) រកឃើញថាពួកជនជាតិដើមទាំងនោះប្រឈមនឹងការមិនមានការយល់ដឹងច្បាស់លាស់ និង មិនមានការយល់ដឹងពីសិទ្ធិរបស់ពួកគាត់ពីអាជ្ញាធរមូលដ្ឋាន។

## ភាពមិនប្រក្រដីនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច

ច្បាប់កម្ពុជាទាមទារអោយមានការធ្វើការវាយតំលៃលើផលប៉ះពាល់ដល់បរិស្ថាន (ESIA) មុននឹងផ្តល់ដីសម្បទាន មានតែការធ្វើការវាយតំលៃលើផលប៉ះពាល់បរិស្ថានទេ (ESIAs) ដែលជាយន្តការដ៏មានសារៈសំខាន់យ៉ាងពិតប្រាកដ ដែលធានាដល់ការផ្តល់ដីសម្បទាន។

ករណីសេដ្ឋីកូឡា រដ្ឋាភិបាលកម្ពុជាអនុម័តអនុក្រឹត្យ ដើម្បីអនុញ្ញាតអោយដីសម្បទានដែលមានទីតាំងក្នុងតំបន់ការពារ។ មានតែក្នុងឆ្នាំ២០១០ ដែលមានការវាយតំលៃលើផលប៉ះពាល់ដល់បរិស្ថាន (ESIA) ដែលធានាការអភិវឌ្ឍន៍លើសម្បទានទាំងពីរ តាមការស្នើសុំពីម្ចាស់ជំនួយអន្តរជាតិ។

ឯកសារទាំងនេះ និងឯកសារពាក់ព័ន្ធនឹងច្បាប់ជាតិ និងកិច្ចសន្យាវិនិយោគបានដាក់ជាសំនួរនីត្យានុកូលភាពនៃដីសម្បទាន ប៉ុន្តែវាក៏បញ្ជាក់ផងដែរពីការខ្វះតម្លាភាពជុំវិញដំណើរការនេះ។

## ការបណ្តេញចេញដោយបង្ខំ ខ្វះខាតការប្រឹក្សាយោបល់ និងសំណងអោយបានគ្រប់គ្រាន់

ដោយប្រើសំពាធទៅលើសហគមន៍ខាងលើ សមាជិកសហគមន៍ទាំងអស់ដែលបានសំភាសន៍បានបញ្ជាក់ថា " **ពួកគាត់គ្មានជំរើសក្នុងការលក់ដីរបស់ពួកគាត់ទេ** "។ ការឈូសឆាយដីបានចាប់ផ្តើមមុនពេលការពិភាក្សាលើសំណងដែលបានបញ្ចប់។ ទោះបីការពិតក្រុមហ៊ុន Socfin-KCD ព្រមទទួលដោះស្រាយបញ្ហា " ក្នុងមធ្យោបាយនៃការពិភាក្សាដែលបានទទួលធ្វើពីដំបូងៗជាមួយសហគមន៍ ការខិតខំប្រឹងប្រែងបន្តបន្ទាប់គឺមិនគ្រប់គ្រាន់ដើម្បីធានានូវការគោរពសិទ្ធិរបស់សហគមន៍ដើម្បីសេរីភាព ការអនុញ្ញាតផ្តល់ដំណឹងពីមុន និង ឈានទៅដល់ការសងសំណងដ៏សមរម្យមួយ។ នៅចុងបញ្ចប់ គ្រួសារដែលទទួលរងនូវការប៉ះពាល់ លើសពី៧ 0% បានទទួលយល់ព្រម ពីព្រោះគ្មានជម្រើសពិតប្រាកដមួយ សំណងជាប្រាក់មិនគ្រប់គ្រាន់និងមិនសមរម្យ និងមានគ្រួសារដទៃទៀតបានជ្រើសរើសទីតាំងដោះដូរថ្មីដែល ពួកគេបានចាកចេញទៅដោយគ្មានការបញ្ជាក់ចង្អុលបង្ហាញថាទីតាំងទាំងនោះនៅឯណាផង។

## ការចិញ្ចឹមជីវិត និងសិទ្ធិវប្បធម៌នៃប្រជាជនព្នងនៅបង្គោលព្រំដី

ការបង្អត់នូវប្រភពចំបងការរស់នៅរបស់ពួកគេ

សហគមន៍ដែលបានទទួលរងនូវផលប៉ះពាល់ឥឡូវត្រូវតែទិញអង្ករ

ដូចនេះពួកគេគឺជាជនងាយរងគ្រោះក្នុងការដែលទីផ្សារកំណត់តំលៃតាមអំពើចិត្ត។ មិនយូរមិនឆាប់

ការខ្វះខាតដើម្បីទទួលបានដីសំរាប់អ្នកភូមិជនជាតិព្នង និងការគ្មានសុវត្ថិភាពចំណីអាហារ

អាចជាសញ្ញានៃការធ្វើអោយមានផលប៉ះពាល់ទៅលើជីវភាពរស់នូវរបស់សហគមន៍។

បន្ថែមលើនេះទៀត ការបំផ្លាញទីតាំងបញ្ចុះសព និងកន្លែងគោរពដូងព្រលឹងផ្សេងៗ

បានបញ្ជាក់ពីផលប៉ះពាល់ទៅលើសុវត្ថិភាពរបស់សហគមន៍ព្នង។

ការមកដល់របស់ប្រជនធ្វើចំណូលស្រុក(Khmer in-migrants)

ធ្វើអោយរឹតតែពិបាកក្នុងការការពារវប្បធម៌របស់អ្នកភូមិ ព្នង។

## ល័ក្ខខ័ណ្ឌការងារដែលមិនទៀងទាត់ពិតប្រាកដ

កម្មករព្នងដែលបានសំភាសន៍បានរអ៊ូរទាំ ពីល័ក្ខខ័ណ្ឌការងារដែលគ្មានភាពទៀងទាត់ពិតប្រាកដ

និងឃោរឃៅ។ ការប៉ុនប៉ងដើម្បីបញ្ចូលការប្រមូលផលស្រូវ និងការងារដាំដុះជាមួយគ្នា

កម្មករព្នងត្រូវបានគេរាយការណ៍ពីឧបទ្ទេវហេតុនៃការនឿយហត់ផ្នែករាងកាយ។

៨០%នៃការធ្វើការងារទាំងអស់បានក្លាយជាការងារប្រចាំថ្ងៃ ជាការងារដែលមិនទៀងទាត់ពិតប្រាកដ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍ចំបង

ករណីនៅប៊ូស្រាបង្ហាញពីអាជ្ញាធរកម្ពុជាថ្នាក់ខ្ពស់បានធ្វើអោយមានភាពស្របច្បាប់

ដែលអនុញ្ញាតសម្បទានទៅជាដីដែលអោយកាន់កាប់ដោយសហគមន៍ក្នុងស្រុក និងជាតំបន់ការពារ។

តាមរយៈអំពើទាំងពីរ នៃសកម្មភាព និងការលុបចោល អាជ្ញាធរកម្ពុជាបានខកខានក្នុងការធានាថាៈ

សហគមន៍ជនជាតិដើមភាគតិចប៉ះពាល់ដោយការធ្វើសម្បទានរឲ្យក្រុមហ៊ុនសុខហ្វីនខេស៊ីឌី (Socfin-KCD) អាចសប្បាយរីករាយនឹងការទទួលបានសិទ្ធិរបស់ពួកគេក្នុងនាមជាជាតិដើមភាគតិច

ប្រកបដោយភាពត្រឹមត្រូវ និងមានអត្ថន័យគ្រប់គ្រាន់ក្នុងការពិភាក្សា ព្រមទាំងផ្តល់សំណាងគ្រប់គ្រាន់

ដោយគោរពតាមច្បាប់ ជាតិ និង ច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស។

ចំណែកឯក្រុមហ៊ុន សុខហ្វីនខេស៊ីឌី Socfin-KCD បានធ្វើសកម្មភាពដោយមិនបានទទួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស។ ក្នុងបរិបទនយោបាយ និងអំពើពុករលួយកំរិតខ្ពស់នៅកម្ពុជា ក្រុមហ៊ុនសុខហ្វីនខេស៊ីឌី Socfin-KCD មិនអាចបដិសេធទៅនឹងបរិបទនូវអ្វីដែលពួកគេកំពុងប្រតិបត្តិឡើយ ហើយពួកគេគួរត្រូវបានគេដឹកនាំដោយយកចិត្តទុកដាក់ ឈានទៅរកភាពប្រុងប្រយ័ត្ន។ ក្រុមហ៊ុនគួរតែត្រូវបានគេដឹងថាមានការវាយតម្លៃពីផលប៉ះពាល់បរិស្ថាននិងសង្គម និងត្រូវបានប្រឹក្សាយោបល់ពីការប៉ះពាល់ទៅជនជាតិដើមភាគតិច។ បន្ទាប់ពីអំពើហិង្សាកើតឡើងម្តងរួចមក ក្រុមហ៊ុន សុខហ្វីន ខេស៊ីឌីSocfin-KCD បានខកខានក្នុងការណាត់ជួបដើម្បីធ្វើការថ្លឹងថ្លែងនូវការសំខាន់ទាំងអស់ ដើម្បីធានាថាអំពើហិង្សាអាចផ្អាក និងតម្រូវទៅតាមដំណើរការសំណងរបស់ខ្លួន និងគោលនយោបាយការងារដើម្បីធានាការគោរពសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌នៃជនជាតិព្នង។

**ហ្វីដ(FIDH) ជម្រុញរាជរដ្ឋាភិបាលកម្ពុជាដើម្បី៖**

- អនុវត្តន៍ភ្លាមៗលើការពន្យារពេលនៃការសងសំណងលើសម្បទានដីសេដ្ឋកិច្ចទាំងអស់ ហើយធ្វើការពិនិត្យឡើងវិញនូវការយល់ព្រមកិច្ចសន្យាលើសម្បទានទាំងអស់ ពន្យាររាល់ដំណើរការនៃការសាងសង់ មិនស្របច្បាប់ទាំងនោះ រហូតទាល់តែមានការព្រមព្រៀង ពីច្បាប់ជាតិ និងអន្តរជាតិ

- សម្របសម្រួលការចុះឈ្មោះអោយបានឆាប់រហ័សរបស់សហគន៍ជនជាតិដើមភាគតិច ហើយធានាពីប្រសិទ្ធភាព និងជំនឿលើពាក្យស្នើសុំនៃការថ្លឹងថ្លែងការការពារ នៅពេលការចុះឈ្មោះស្របច្បាប់ទាំងអស់ ឬក៏ប្រមូលរាល់ការដាក់ឈ្មោះដែលមិនមានសុវត្ថិភាព

- ធានាថាការប្រឹក្សាយោបល់ពិតជាមានអត្ថន័យគ្រប់គ្រាន់ ហើយការចូលរួមរបស់សហគមន៍មានអនុភាពលើដីសម្បទានសេដ្ឋកិច្ច ដោយរួមបញ្ចូលការស្វះស្វែងរកសិទ្ធិសេរីភាព ការផ្តល់ព័ត៌មានជាមុន

- បង្កើតយន្តការត្រួតពិនិត្យដោយឯករាជ្យទៅលើការធ្វើជំនួញកសិកម្មទ្រង់ទ្រាយធំ ដើម្បីធានាការគោរពស្តង់ដារសិទ្ធិមនុស្ស និងការទទួលខុសត្រូវលើការវិនិយោគកសិកម្មដែលមានការចូលរួមពីតំណាងសង្គមស៊ីវិល

- ធានាឲ្យបាននូវផលប៉ះពាល់ដល់រូបរាងកាយ និងផ្លូវចិត្ត ទៅលើការការពារសិទ្ធិមនុស្សនៅកម្ពុជា រួមបញ្ចូលទាំងការការពារសិទ្ធិដីធ្លី

**ហ្វីដ(FIDH) បង្គាប់ទៅសុខហ្វីនខេស៊ីឌីដើម្បីៈ**

- ពន្យារាល់ដំណើការទាំងអស់របស់ក្រុមហ៊ុនរហូតដល់ជម្លោះបច្ចុប្បន្នត្រូវបានដោះស្រាយ

- ដាក់រាល់អនុសាសន៍នៃការវិភាគលើផលប៉ះពាល់បរិស្ថានឆ្នាំ2010 រួមបញ្ចូលការវាស់វែងលើការការពារនូវប្រពៃណីរបស់ជនជាតិព្នង និងដើម្បីធានាថាជីវិតរស់នៅរបស់ពួកគេមាននិរន្តរភាព

- ធ្វើការពិនិត្យសារឡើងវិញលើសំណាងដែលបានផ្តល់អោយដើម្បីធានាអោយសមស្របស្តង់ដារ អន្តរជាតិ រួមបញ្ចូលទាំងសំណាងចំពោះការបំផ្លាញក្រមសីលធម៌

**ហ្វីដ FIDH បានស្នើសុំអោយប្រទេសលុចហ្សំបួរ និង សហគមន៍អ៊ឺរ៉ុប ចូលរួមដូចតទៅៈ**

- អនុម័តច្បាប់ និងគោលនយោបាយដែលអាចអនុវត្តបាន ដើម្បីធានាថាវិស័យឯកជនមានការចុះបញ្ជីដោយស្របច្បាប់ក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួនដែលនឹងអាចឈានទៅដល់ការទទួលខុសត្រូវសង្គម ចំពោះការរំលោភសិទ្ធិមនុស្ស និង ជនរងគ្រោះទាំងនោះដើម្បីទទួលបាននូវការដំណោះស្រាយប្រកបការគោរពសិទ្ធិមនុស្សដ៏មានប្រសិទ្ធភាពមួយ។

- ទាមទារអោយអ្នកទទួលបន្តពាយនាមនៅក្នុងភ្នាក់ងារចែកចាយ លុចហ្សំបួ បើកចំហរអំពីផលប៉ះពាល់សង្គម និង បរិស្ថានពីសកម្មភាពរបស់ពួកគេ(រួមបញ្ចូលទាំងម្ចាស់ភាគហ៊ុនរបស់ពួកគេ)

**FIDH represents 164 human rights organisations on 5 continents**



of person. Article 4: No one shall be held in slavery or servitude; slavery and the slave trade shall be prohibited in all their forms. Article 5: No one shall be subjected to torture or to cruel, inhuman or degrading treatment or punishment. Article 6: Everyone has the right to recognition everywhere as a person before the law. Article 7: All are equal before the law and are entitled without any discrimination to equal protection of the law. All are entitled to equal protection against any discrimination in violation of this Declaration and against any incitement to such discrimination. Article 8: Everyone has the right to an effective remedy by the competent national tribunals for acts violating the fundamental rights granted him by the constitution or by law. Article 9: No one shall be subjected to arbitrary arrest,

# ABOUT FIDH

- FIDH takes action for the protection of victims of human rights violations, for the prevention of violations and to bring perpetrators to justice.

- A broad mandate
FIDH works for the respect of all the rights set out in the Universal Declaration of Human Rights: civil and political rights, as well as economic, social and cultural rights.

- A universal movement
FIDH was established in 1922, and today unites 164 member organisations in more than 100 countries around the world. FIDH coordinates and supports their activities and provides them with a voice at the international level.

- An independent organisation
Like its member organisations, FIDH is not linked to any party or religion and is independent of all governments.

**FIDH - International Federation for Human Rights**
17, passage de la Main-d'Or - 75011 Paris - France
CCP Paris: 76 76 Z
Tel: (33-1) 43 55 25 18 / Fax: (33-1) 43 55 18 80
www.fidh.org

Director of the publication: Souhayr Belhassen / Editor: Antoine Bernard
Imprimerie de la FIDH - Dépôt légal décembre 2011 - FIDH ISSN en cours - Fichier informatique conforme à la loi du 6 janvier 1978 (Déclaration N°330 67